# ការចាក់ដូសបន្ថែមសម្រាប់មនុស្សដែលមានប្រព័ន្ធភាពស៊ាំខ្សោយ

## (ដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ)

មនុស្សដែលមានប្រព័ន្ធភាពស៊ាំខ្សោយទំនងជាអាចឆ្លងជំងឺ COVID-19 ជាងមនុស្សដែលមានប្រព័ន្ធភាពស៊ាំធម្មតា។ ហើយប្រសិនបើពួកគេឆ្លងមេរោគ ពួកគេទំនងជាធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ និងចម្លងមេរោគដល់មនុស្សដទៃទៀតនៅក្នុងផ្ទះរបស់ពួកគេ។

ការសិក្សានានាបានបង្ហាញថាមនុស្សមួយចំនួន ដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ មិនអាចបង្កើតការការពារគ្រប់គ្រាន់ទេ បន្ទាប់ពីបានចាក់ថ្នាំបង្ការប្រភេទ Pfizer ឬ Moderna ចំនួនទាំង 2 ដូសនោះ។

**ដោយសារតែបញ្ហានេះ មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) បានណែនាំឱ្យប្រជាជនដែលមានភាពស៊ាំចុះខ្សោយកម្រិតមធ្យមដល់ធ្ងន់ធ្ងរ ឱ្យទៅទទួលបានការចាក់ដូសបន្ថែម។ នេះរាប់បញ្ចូលមនុស្សដែល៖**



- ធ្លាប់បានទទួលការព្យាបាលជំងឺមហារីកជាប្រចាំចំពោះការព្យាបាលដុំសាច់ដុះ ឬជំងឺមហារីកកោសិកាឈាមផ្សេងៗ
- បានទទួលការប្តូរសរីរាង្គ ហើយកំពុងប្រើថ្នាំដើម្បីបង្ក្រាបប្រព័ន្ធភាពស៊ាំ
- បានទទួលការប្តូរកោសិកាដើមក្នុងអំឡុងពេល 2 ឆ្នាំកន្លងមក ឬកំពុងប្រើថ្នាំដើម្បីបង្ក្រាបប្រព័ន្ធភាពស៊ាំ
- ប្រព័ន្ធភាពស៊ាំខ្វះខាតបឋម (primary immunodeficiency) កម្រិតធ្ងន់ធ្ងរ ឬមធ្យម (ដូចជារោគសញ្ញា DiGeorge រោគសញ្ញា Wiskott-Aldrich)
- ការឆ្លងមេរោគអេដស៍ (HIV) កម្រិតធ្ងន់ ឬមិនបានព្យាបាល
- ការព្យាបាលយ៉ាងជាប់លាប់ដោយប្រើថ្នាំប្រឆាំងនឹងការរលាកកោសិកា (corticosteroids) ដែលអាចកម្រិតខ្ពស់ ឬថ្នាំដទៃទៀតដែលបង្ក្រាបការឆ្លើយតបនៃប្រព័ន្ធភាពស៊ាំ

សូមពិគ្រោះជាមួយគ្រូពេទ្យរបស់អ្នកអំពីការទទួលការចាក់ថ្នាំបង្ការជំងឺ COVID-19 ដូសបន្ថែម។ ប្រសិនបើអ្នកត្រូវការចាក់ដូសទី 3 សូមសាកសួរអំពីពេលវេលាដែលល្អបំផុត ដោយផ្អែកលើផែនការព្យាបាលជំងឺរបស់អ្នកនាពេលបច្ចុប្បន្ន។ នេះមានសារៈសំខាន់ខ្លាំងណាស់ ប្រសិនបើអ្នកហៀបនឹងចាប់ផ្តើមការព្យាបាលទាក់ទងនឹងការបង្ក្រាបភាពស៊ាំ (immunosuppressive treatment) ឬចាប់ផ្តើមវាឡើងវិញ។

**អ្នកក៏គួរតែដឹងដែរ៖**



- គួរតែត្រូវបានចាក់ជូនដូសទី 3 នៃប្រភេទថ្នាំបង្ការ mRNA (ដូចជាថ្នាំបង្ការប្រភេទ Pfizer និង Moderna) ដោយមានគម្លាតយ៉ាងហោចណាស់ 28 ថ្ងៃបន្ទាប់ពីការចាក់ដូសទី 2។
- គួរតែប្រើថ្នាំបង្ការប្រភេទដូចគ្នា ប្រសិនបើអាចធ្វើបាន។ ឧទាហរណ៍ ប្រសិនបើអ្នកបានចាក់ថ្នាំបង្ការប្រភេទ Pfizer សូមព្យាយាមចាក់ថ្នាំបង្ការប្រភេទ Pfizer ផងដែរសម្រាប់ដូសទី 3 របស់អ្នក។
- បច្ចុប្បន្នការចាក់ដូសបន្ថែម មិនត្រូវបានណែនាំដល់អ្នកដែលបានចាក់ថ្នាំបង្ការ Johnson & Johnson ទេ។ រដ្ឋបាលចំណីអាហារនិងឱសថរបស់អាមេរិក (FDA) នៅតែកំពុងវាយតម្លៃទិន្នន័យស្តីពីប្រសិទ្ធភាពនៃថ្នាំបង្ការនេះ ចំពោះបុគ្គលដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ។